**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុប្រជុំ
# ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ម៉ោង១៥:២០នាទីរសៀល នៅក្នុងក្រុមហ៊ុន យ៉ាវ ហួរព្រីនវើក ដែលមានអាសយដ្ឋានផ្ទះលេខ99 ផ្លូវ 371 ភូមិម៍ល សង្កាត់ដង្កោ ខណ្ឌ ដង្កោ ភ្នំពេញ។បានបើកកិច្ចប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន១៥៦នាក់ រយៈពេល០២ ខែ គិតចាប់ពីថ្ងៃ០៤ ខែ ឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០។

I. **សមាសសភាពចូលរួមរួមមានដូចតទៅៈ**

1. លោកស្រី CHEN HAIYU — នាយកក្រុមហ៊ុនយ៉ាវ ហួរ
2. អ្នកស្រី វឿត ចន្ទី — រដ្ឋបាល
3. យ៉ន ធាវ៉ានី — គណនេយ្យករ
4. បាវ យឿន — ជំនួយការ
5. ឆេង ធី — ប្រធានតំណាងប្រតិភូ
6. ឈាន វណ្ណថា — តំណាងប្រតិភូ
7. មៀច ណយ — តំណាងប្រតិភូ

ជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំ អ្នកស្រី វឿត ចន្ទី ដែលជាអ្នកសម្របសម្រួលក្នុងអង្គប្រជុំបានធ្វើការពន្យល់ណែនាំពីការខ្វះខាតវត្ថុធាតុដើម សម្ភារ និងការលុបចោលការបញ្ជាទិញរបស់ភ្ញៀវ ដែលបណ្តលឲ្យបងប្អូនកម្មករនិយោជិតទាំងអស់គ្មានការធ្វើ ព្រមទាំងបញ្ហាការរីករាលដាល ការឆ្លងជំងឺកូវីដ-១៩ Covid-19 ទូទាំងសកលលោកនិងការណែនាំស្តីពីនីតិវិធីនៃការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតជូនដល់អង្គប្រជុំទាំងមូលបានជ្រាប។

II. **ក្រោយពីបានឆ្លងកាត់ការប្រជុំ**
**និងពិភាក្សាគ្នារួចមកភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោម ៖**

១-ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៥៦នាក់ដូចមានជូនភ្ជាប់ក្នុងបញ្ជីឈ្មោះជាមួយរយៈពេល ០២ខែ ចាប់ពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០និងត្រូវចូលធ្វើការងារជាធម្មតាវិញនៅថ្ងៃទី០៤ ខែកក្កដាឆ្នាំ២០២០តាមកាលកំណត់។

២-ក្រុមហ៊ុនឯកភាពផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០$ដុល្លារ ខែតី១ក្នុង(សាមសិបដុល្លារអាមេរិក) ក្រុមហ៊ុនបានអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

៣-ចំពោះការបើកប្រាក់ព្យួរកិច្ចសន្យាការងារចំនួន ៣០$ដុល្លារក្នុងមួយខែខាងលើ គឺត្រូវបើកនៅថ្ងៃទី ១០នៃបំណាច់ខែនីមួយៗ។

Scanned with CamScanner

កំណត់ហេតុអង្គប្រជុំនេះ ត្រូវបានបញ្ចប់ទៅនៅវេលាម៉ោង ១៥និង២០ រសៀល នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសឃោគយល់អធ្យាស្រ័យ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃទីព្រហស្បតិ៍ ៩កើត ខែពិសាខឆ្នាំជូតទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២០

ហត្ថលេខានិងត្រា

ស្នាមមេដៃស្តាំតំណាងកម្មករ និងប្រធានក្រុម

រដ្ឋបាលនិងគណនេយ្យ



Scanned with CamScanner